01072103

002/19-09-2007-ECCC/TC
E1/253

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 03 / 2015
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

# ថ្ងៃ អង្គារ ទី ២៧ ខែ មករា ឆ្នាំ ២០១៥

# សវនាការលើភស្តុតាង - ថ្ងៃ ២៣៤

រៀបចំដោយ៖ សែ គុលវុឌ្ឍី និង **Matthew McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ង, លោក Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង ប៊ុនឃាង, កញ្ញា ស៊ុង ធវន្ត, លោក Joseph Andrew BOYLE, លោក ស្រ៊ា រតនៈ, លោក Vincent de WILDE d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីបម្រុងរបស់ខៀវ សំផន: លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ហុង គីមសួន, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ទី ស្រីនណា |
| សាក្សី/ដើមបណ្ដឹង៖ លោកស្រី ជូ គឹមឡុន (2-TCCP-238), លោក ឯម អឿង (2-TCW-954) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, កញ្ញា ស្វ សុទ្ធារី |
| ផ្សេងៗ៖ លោក មៀច សុវណ្ណា, កញ្ញា សុក សុភ័គមណីកា, លោក នូ មនោរត្ន័, កញ្ញា ស្រី ណាក់ កញ្ញា តូច តន់នារី, លោក Mario D'ALESSANDRO |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៥.៥០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៦ |
| ការស្នើសុំលះបង់សិទ្ធិរបស់ នួន ជា ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ | អង្គជំនុំជម្រះ | ០៩.០៧ | ០៩.១០ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡុន (2-TCCP-238) | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា<br><br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.១០<br>០៩.៤៦<br>១០.៣៧<br>១៣.៣០ | ០៩.៤៥<br>១០.១១<br>១១.៣៣<br>១៥.១៧ |
| សេចក្ដីសម្រេចផ្ទាល់មាត់លើសម្បទារបស់ជនជាប់ចោទទាំងពីរ | អង្គជំនុំជម្រះ | ១០.៣៣ | ១០.៣៧ |
| ការថ្លែងអំពីទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី | ដើមបណ្ដឹងរដ្ឋប្បវេណី | ១៥.១៨ | ១៥.៣០ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅកាន់សាក្សី ឯម ភឿង (2-TCW-954) | អង្គជំនុំជម្រះ | ១៥.៣៦ | ១៥.៤៨ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីបានធ្វើការរាយការណ៍ថា គ្រប់ភាគីទាំងអស់ មានវត្តមាន លើកលែងតែជនជាប់ចោទ នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីពីការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពី បន្ទប់សវនាការ ទៅតាមដានសវនាការនៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ អង្គជំនុំជម្រះ សម្រេចអនុញ្ញាតិឲ្យ នួន ជា តាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន (2-TCCP-238)</u>**

អង្គជំនុំជម្រះបានសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់មកមេធាវីការពារក្ដី នួន ជា និង មេធាវីការ ពារក្ដី ខៀវ សំផន។ ជាចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់អំពីការឈឺចាប់ និងព្យសន កម្មដែលទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**<u>សេចក្ដីសម្រេចផ្ទាល់មាត់លើសម្បទារបស់ជនជាប់ចោទទាំងពីរ</u>**

ដោយអនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង និងយោងតាមអនុសាសន៍លើការវាយតម្លៃរបស់អ្នក ជំនាញទាំងពីរទៅលើសម្បទារបស់ជនជាប់ចោទនោះ អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទទាំងពីរ នួន ជា និង ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ តាមអនុសាសន៍របស់ អ្នកជំនាញ អង្គជំនុំជម្រះនឹងបង្គាប់ឲ្យមានពិនិត្យ និងតាមដានលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ ឲ្យបានសមស្រប។ អង្គជំនុំជម្រះ ក៏នឹងកែសម្រួលកាលវិភាគនៃការធ្វើសវនាការក្នុងពេលបច្ចុប្បន្ននេះ ផងដែរ។ ហេតុដូច្នេះ ចាប់ពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ នេះតទៅ អង្គជំនុំជម្រះនឹងចាប់ផ្ដើមសវនា ការពីម៉ោង ៩.០០ ព្រឹក ហើយសម្រាកអាហារថ្ងៃត្រង់នៅវេលាម៉ោង ១១.៣០ នាទី និងបន្តសវនាការ ពីម៉ោង ១៣.៣០ នាទី ដល់ម៉ោង ៤.០០ ល្ងាច។ ចាប់ពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ខាងមុខនេះតទៅ អង្គជំនុំជម្រះនឹងធ្វើសវនាការ ៤ ថ្ងៃ ក្នុងមួយសប្ដាហ៍ ពីថ្ងៃ ច័ន្ទ ដល់ ព្រហស្បត្តិ៍ តាមដែលអាចធ្វើទៅ បាន។ អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីក្នុងពេលឆាប់ៗខាងមុខនេះ ពីកាលវិភាគសវនាការដែល បានកែតម្រូវ និងពីលំដាប់លំដោយនៃការកោះហៅសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែល ត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនាពេលបច្ចុប្បន្ននេះ។

**ការថ្លែងអំពីទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

ដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការថ្លែងនូវទុក្ខសោក និងព្យសនកម្មផ្ទាល់ខ្លួន ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ការតាំងសំណួរទៅកាន់សាក្សី ឯម អឿង (2-TCW-954)**

អង្គជំនុំជម្រះបានតាំងសំណួរមួយចំនួនទៅសាក្សី។ បន្ទាប់មកសាក្សីបានជូនដំណឹងដល់អង្គជំនុំជម្រះពីភាពមិនអាចចូលរួមផ្ដល់សក្ខីកម្មរបស់ខ្លួននៅសវនាការថ្ងៃស្អែកបាន។ អង្គជំនុំជម្រះបានសម្រេច កែប្រែកាលបរិច្ឆេទនៃការស្ដាប់សក្ខីកម្មរបស់សាក្សី ទៅថ្ងៃណាមួយដែលសាក្សីអាចចូលរួមបាននៅសប្ដាហ៍ខាងមុខទៀត។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខ កសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5635 | | 00897420-00897427<br>00678302-00678308<br>00898378-00898382 | Witness statement of CHOU Koemlan | P | 00897420<br>00897422<br>00897423 | 00678302<br>00678304 | 00898378<br>00898379<br>00898380 |
| E3/5840 | D22/2502/1 | 01053476-01053478<br>00550930-00550931 | Victims Unit Report on civil party applicant | P | 01053477 | 00550930-00550931 | / |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ នឹងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥។

01072107



| <u>កាលវេលាសវនាការបន្ត</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលទុទ្ធ** **atthew McCARTHY**